ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល
នាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង
ការិយាល័យឱសថសារវ័ន្ត

# គោលការណ៍ណែនាំស្តីពីប្រព័ន្ធហ្វាម៉ាកូវីជីឡែនសម្រាប់ កម្មវិធីជាតិក្នុងកិច្ចអន្តរាគមន៍សុខភាពសាធារណៈ




រៀបចំដោយមណ្ឌលព័ត៌មានឱសថកម្ពុជា
ឧបត្ថម្ភថវិកាដោយ: គម្រោងមូលនិធិសកល NFM Malaria Grant
បោះពុម្ពលើកទី ១
ខែ............... ឆ្នាំ ២០២០

## អារម្ភកថា

ការធានាសុវត្ថិភាពនិងគុណភាពរបស់ឱសថមានគោលបំណងធានាសុវត្ថិភាពឱសថតាមរយៈការផ្លាស់ប្តូរព័ត៌មានដែលគួរឱ្យទុកចិត្ត និងទាន់ពេលវេលាស្តីពីបញ្ហាសុវត្ថិភាពឱសថដោយជំរុញសកម្មភាពហ្វាម៉ាកូវីជីឡែន (Pharmacovigilance) ទូទាំងប្រទេស ហើយលើកទឹកចិត្តឱ្យមានការចូលរួមក្នុងកម្មវិធីរបស់អង្គការសុខភាពពិភពលោកដើម្បីតាមដានសុវត្ថិភាពឱសថជាអន្តរជាតិ។ គោលការណ៍ណែនាំស្តីពីហ្វាម៉ាកូវីជីឡែន(Pharmacovigilance) សម្រាប់កម្មវិធីជាតិក្នុងកិច្ចអន្តរាគមន៍សុខភាពសាធារណៈត្រូវបានបង្កើតឡើងដោយមានការពិគ្រោះយោបល់ជាមួយអ្នកឯកទេសហ្វាម៉ាកូវីជីឡែន (Pharmacovigilance) អន្តរជាតិ និងកម្មវិធីជាតិក្នុងកិច្ចអន្តរាគមន៍សុខភាពសាធារណៈមកពីមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺរបេង និងហង់សិន មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ និងកម្មវិធីជាតិចាក់ថ្នាំបង្ការ។

ហ្វាម៉ាកូវីជីឡែន(Pharmacovigilance)គឺជាផ្នែកសម្រាប់ថែទាំអ្នកជំងឺ។ វាមានគោលបំណងធ្វើឱ្យការប្រើប្រាស់ឱសថបានល្អត្រឹមត្រូវសម្រាប់ការព្យាបាល ឬការបង្ការជំងឺ។ គ្មាននរណាម្នាក់ចង់ធ្វើឱ្យអ្នកជំងឺឈឺចាប់នោះទេ តែជាអកុសលឱសថខ្លះនឹងបង្កឱ្យមានបញ្ហា។ ប្រព័ន្ធហ្វាម៉ាកូវីជីឡែន (Pharmacovigilance) ល្អនឹងកំណត់អត្តសញ្ញាណហានិភ័យ និងកត្តាហានិភ័យក្នុងរយៈពេលខ្លីបំផុតដែលអាចធ្វើទៅបាន ដូច្នេះផលប៉ះពាល់អាចត្រូវបានជៀសវាង ឬកាត់បន្ថយបាន។ នៅពេលដែលទំនាក់ទំនងមានប្រសិទ្ធភាពល្អ ព័ត៌មាននេះអាចគិតពិចារណាអំពីការប្រើឱសថដែលផ្អែកលើភស្តុតាងហើយមានសក្តានុពលក្នុងការទប់ស្កាត់ប្រតិកម្មរំខានរបស់ឱសថជាច្រើន។ គោលការណ៍ណែនាំនេះនឹងជួយអ្នកជំងឺម្នាក់ៗឱ្យទទួលបានការព្យាបាលល្អប្រសើរ ហើយនិងជួយធានាឱ្យការទទួលស្គាល់ និងប្រសិទ្ធភាពរបស់កម្មវិធីជាតិក្នុងកិច្ចអន្តរាគមន៍សុខភាពសាធារណៈពីសំណាក់ប្រជាជនទូទៅ។ ផលប៉ះពាល់ខ្លាំងដល់អ្នកជំងឺមួយចំនួនអាចបំផ្លាញការជឿជាក់ ការគោរពតាម និងភាពជោគជ័យរបស់កម្មវិធីជាតិ។ ពាក្យចចាមអារ៉ាម និងជំនឿមិនត្រឹមត្រូវអំពីផលរំខានរបស់ឱសថអាចរីករាលដាលយ៉ាងឆាប់រហ័ស និងពិបាកក្នុងការបង្ហាញថាមិនត្រឹមត្រូវប្រសិនបើគ្មានទិន្នន័យល្អ។ ហ្វាម៉ាកូវីជីឡែន (Pharmacovigilance) អាចផ្តល់ទិន្នន័យល្អទាំងនេះបាន។ វាក៏អាចផ្តល់ភស្តុតាងប្រភេទផ្សេងទៀតនៃបញ្ហាដែលទាក់ទងនឹងការប្រើឱសថ រួមទាំងការបរាជ័យក្នុងការព្យាបាលដោយឱសថក្លែងក្លាយ ឱសថអន់គុណភាព អន្តរកម្មរវាងឱសថនិងចំណីអាហារ និងការប្រើប្រាស់ឱសថមិនត្រឹមត្រូវ។ គោលការណ៍អនុវត្តល្អក្នុងហ្វាម៉ាកូវីជីឡែន (Pharmacovigilance) អាចជំរុញទំនុកចិត្ត និងការជឿជាក់របស់សាធារណជនមកលើវិស័យសុខាភិបាល។

ឯកសារនេះបង្ហាញថា pharmacovigilance អាចជាផ្នែកមួយដ៏សំខាន់នៃរាល់កម្មវិធីជាតិក្នុងកិច្ចអន្តរាគមន៍សុខភាពសាធារណៈដែលប្រើឱសថ ដើម្បីពង្រឹងការងារគ្រប់គ្រងឱសថឱ្យកាន់តែប្រសើរ និងទប់ស្កាត់សោកនាដកម្មដែលអាចនឹងកើតមាន។

ថ្ងៃ ពុធ ៤រោច ខែ មាឃ ឆ្នាំ កុរ ឯកស័ក ពុទ្ធសករាជ ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០២០

រដ្ឋមន្ត្រីក្រសួងសុខាភិបាល

រដ្ឋមន្ត្រី

វេជ្ជ. ម៉ម ប៊ុនហេង

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុតចំពោះ គណៈកម្មការបច្ចេកទេសព័ត៌មានឱសថកម្ពុជា ដែលបានចូលរួមពិនិត្យ និងរៀបចំបង្កើតនូវឯកសារ **"គោលការណ៍ណែនាំស្តីពីប្រព័ន្ធហ្វាម៉ាកូវីជីឡែនសម្រាប់កម្មវិធីជាតិក្នុងកិច្ចអន្តរាគមន៍សុខភាពសាធារណៈ"** តាមរយៈសិក្ខាសាលាពិគ្រោះយោបល់ ដោយបានផ្តល់នូវយោបល់ល្អៗ ធ្វើឱ្យឯកសារនេះបានរៀបចំរួចប្រកបដោយអត្ថន័យគ្រប់គ្រាន់សម្រាប់យកមកអនុវត្តការងារដែលទាក់ទងព័ត៌មានឱសថ។

| | | |
|---|---|---|
| ១ | ឯកឧត្តមសាស្ត្រាចារ្យ ម៉ម ប៊ុនហេង | រដ្ឋមន្ត្រីក្រសួងសុខាភិបាល |
| ២ | លោកជំទាវវេជ្ជបណ្ឌិត ឱ វណ្ណឌីន | រដ្ឋលេខាធិការក្រសួងសុខាភិបាល |
| ៣ | ឯកឧត្តមវេជ្ជបណ្ឌិត ហុក គឹមចេង | អគ្គនាយកបច្ចេកទេសសុខាភិបាល |
| ៤ | លោកឱសថការី ហ៊ុន ហួង | អគ្គនាយករងបច្ចេកទេសសុខាភិបាល |
| ៥ | លោកឱសថបណ្ឌិត ហេង ប៊ុនគៀត | ប្រធាននាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង |
| ៦ | លោកឱសថបណ្ឌិត យ៉ង់ ដារាវុធ | អនុប្រធាននាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង |
| ៧ | លោកវេជ្ជបណ្ឌិត ឡឹក ឌីសូឡី | អនុប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធប្រឆាំងជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រ និងបាណកសាស្ត្រ |
| ៨ | លោកវេជ្ជបណ្ឌិត ទៀង ស៊ីវណ្ណា | អនុប្រធានមជ្ឈមណ្ឌលជាតិកំចាត់រោគរបេង និងហង់សិន |
| ៩ | លោកឱសថការី សៀ ថុល | ប្រធានការិយាល័យឱសថសាវន្ត |
| ១០ | លោកឱសថបណ្ឌិត ជៀប ធនវុឌ្ឍី | អនុប្រធានការិយាល័យឱសថសាវន្ត និងជាប្រធានមណ្ឌលព័ត៌មានឱសថកម្ពុជា |
| ១១ | លោកឱសថបណ្ឌិត ជួន វិបុល | មន្ត្រីមណ្ឌលព័ត៌មានឱសថកម្ពុជា |
| ១២ | លោកវេជ្ជបណ្ឌិត ហោ ស្រ៊ុន | មន្ត្រីមណ្ឌលព័ត៌មានឱសថកម្ពុជា |
| ១៣ | លោកឱសថការី ស៊ី រ៉ាម៉ុល | មន្ត្រីមណ្ឌលព័ត៌មានឱសថកម្ពុជា |
| ១៤ | លោកឱសថការី ចែម ឡុងឌី | មន្ត្រីមណ្ឌលព័ត៌មានឱសថកម្ពុជា |
| ១៥ | លោកឱសថការី ផុល ពន្លឺ | អនុប្រធានមន្ទីរសុខាភិបាលខេត្តត្បូងឃ្មុំ |
| ១៦ | កញ្ញាឱសថការី ឌិត គីមមាន | ប្រធានការិយាល័យឱសថមន្ទីរសុខាភិបាលខេត្តកោះកុង |
| ១៧ | លោកឱសថការី ជុំ ម៉េត | ប្រធានការិយាល័យឱសថមន្ទីរសុខាភិបាលខេត្តតាកែវ |
| ១៨ | លោកឱសថការី ង៉ូវ សូជោត | ប្រធានការិយាល័យឱសថមន្ទីរសុខាភិបាលខេត្តក្រចេះ |
| ១៩ | លោកឱសថការី ហួត រិទ្ធីនរៈ | ប្រធានការិយាល័យឱសថមន្ទីរសុខាភិបាលខេត្តមណ្ឌលគីរី |
| ២០ | លោកឱសថការី ហាស់ អសនី | ប្រធានការិយាល័យឱសថមន្ទីរសុខាភិបាលខេត្តបាត់ដំបង |
| ២១ | លោកស្រីឱសថការី អ៊ីវ លីដា | អនុប្រធានការិយាល័យឱសថមន្ទីរសុខាភិបាលខេត្តសៀមរាប |
| ២២ | លោកឱសថការី ដួង ហៀង | អនុប្រធានការិយាល័យឱសថមន្ទីរសុខាភិបាលខេត្តបន្ទាយមានជ័យ |
| ២៣ | លោកស្រី ពេជ គីមភ័រ | អនុប្រធានការិយាល័យឱសថមន្ទីរសុខាភិបាលខេត្តកំពង់ចាម |

| | | |
|---|---|---|
| ២៤ | លោក អ៊ុំ សុភី | មន្ត្រីការិយាល័យឱសថមន្ទីរសុខាភិបាលខេត្តកំពង់ស្ពឺ |
| ២៥ | លោកស្រីឱសថការី វង្ស ណារ៉ុន | មន្ត្រីការិយាល័យឱសថមន្ទីរសុខាភិបាលខេត្តកំពត |
| ២៦ | លោកឱសថការី ប៊ិច ថារ៉ាត | មន្ត្រីការិយាល័យឱសថមន្ទីរសុខាភិបាលខេត្តត្បូងឃ្មុំ |
| ២៧ | លោកទុន ពេជ្រ | មន្ត្រីការិយាល័យឱសថមន្ទីរសុខាភិបាលខេត្តត្បូងឃ្មុំ |
| ២៨ | លោកឱសថការី ខេង ម៉ូណា | មន្ត្រីការិយាល័យឱសថមន្ទីរសុខាភិបាលខេត្តពោធិ៍សាត់ |
| ២៩ | លោកស្រីឱសថការី កែវ សិរីវឌ្ឍនៈ | មន្ត្រីការិយាល័យឱសថមន្ទីរសុខាភិបាលខេត្តឧត្តរមានជ័យ |
| ៣០ | លោកឱសថការី អ៊ុង រតនាសម្បត្តិ | មន្ត្រីការិយាល័យឱសថមន្ទីរសុខាភិបាលខេត្តរតនៈគិរី |
| ៣១ | លោកឱសថការី ចាន់ រ៉ាវី | មន្ត្រីការិយាល័យឱសថមន្ទីរសុខាភិបាលខេត្តកំពង់ធំ |
| ៣២ | លោកឱសថការី ម៉ម ពិសិដ្ឋ | មន្ត្រីការិយាល័យឱសថមន្ទីរសុខាភិបាលខេត្តកែប |
| ៣៣ | លោកឱសថការី សុខ ធវន្ត | មន្ត្រីការិយាល័យឱសថមន្ទីរសុខាភិបាលខេត្តកំពង់ឆ្នាំង |
| ៣៤ | លោកឱសថការី គី កែវសំរិទ្ធ | មន្ត្រីការិយាល័យឱសថមន្ទីរសុខាភិបាលខេត្តព្រះសីហនុ |
| ៣៥ | លោកឱសថការី ស៊ុន ម៉ាឌីណា | មន្ត្រីការិយាល័យឱសថមន្ទីរសុខាភិបាលខេត្តស្ទឹងត្រែង |
| ៣៦ | លោកស្រីឱសថការី យី វង្សី | ប្រធានឱសថស្ថាននៃមជ្ឈមណ្ឌលជាតិគាំពារមាតានិងទារក |
| ៣៧ | លោកឱសថការី ចាន់ ដារ៉ូ | ប្រធានឱសថស្ថាននៃមន្ទីរពេទ្យព្រះកុសមៈ |
| ៣៨ | លោកឱសថការី អែ វឌ្ឍនៈ | អនុប្រធានឱសថស្ថាននៃមន្ទីរពេទ្យមិត្តភាពខ្មែរសូវៀត |
| ៣៩ | លោកវេជ្ជបណ្ឌិត ឡោ ផារិទ្ធ | មន្ត្រីកម្មវិធីជាតិចាក់ថ្នាំបង្ការ |
| ៤០ | លោកឱសថការី ប្រុក កាហៀញ | ប្រធានគ្រប់គ្រងផ្នែកឱសថ ប្រតិករ និងសម្ភារៈបរិក្ខារពេទ្យនៃមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ |
| ៤១ | លោកឱសថការី ទៀង ស៊ុនលី | មន្ត្រីកិច្ចសន្យាមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍សើស្បែក និងកាមរោគ |
| ៤២ | លោក ឃ្លោក ច័ន្ទតារា | មន្ត្រីគម្រោង GF មណ្ឌលព័ត៌មានឱសថកម្ពុជា |
| ៤៣ | កញ្ញាឱសថការី ហេន សូដេន | មន្ត្រីគម្រោង GF មណ្ឌលព័ត៌មានឱសថកម្ពុជា |
| ៤៤ | Mr. Syed RizwanuddinAhman | ទីប្រឹក្សាមណ្ឌលព័ត៌មានឱសថកម្ពុជា |

យើងខ្ញុំក៏សូមថ្លែងអំណរគុណផងដែរចំពោះតំណាងគ្រឹះស្ថានអាហារ៉ែនីហារ៉ែឱសថនិងសហគ្រាសផលិតឱសថមួយចំនួនដែលបានយកចិត្តទុកដាក់ចូលរួមផ្តល់នូវមតិល្អៗ ដើម្បីរៀបចំនូវឯកសារនេះ។

| | | |
|---|---|---|
| ១ | លោក ជា ចំណាន | ប្រធានសហគ្រាសផលិតឱសថ ជា ចំណាន |
| ២ | លោក ផេង ស្រ៊ុង | សហគ្រាសផលិតឱសថ Ephac |
| ៣ | លោកឱសថការី កៅ មួយលីម | សហគ្រាសផលិតឱសថ Ephac |
| ៤ | កញ្ញាឱសថការី សុខា និមល | អ្នកទទួលបន្ទុកផ្នែកនិយ័តកម្ម និងពាណិជ្ជកម្មរបស់ក្រុមហ៊ុន DKSH |
| ៥ | លោកវេជ្ជបណ្ឌិត គុជ សុថារិទ្ធិ | ប្រធានផ្នែកនិយ័តកម្ម និងពាណិជ្ជកម្មរបស់ក្រុមហ៊ុន Bayer |
| ៦ | លោកវេជ្ជបណ្ឌិត លឹម ហ៊ុយ | ប្រធានផ្នែកវេជ្ជសាស្ត្ររបស់ Sanofi Cambodia |
| ៧ | លោកឱសថការី ជា យ៉ុន | នាយកគ្រប់គ្រងនិយ័តកម្ម និងពាណិជ្ជកម្មរបស់ Labo Servier |

**កែសម្រួលពីឯកសារ**

១. គោលការណ៍ណែនាំថ្នាក់ជាតិប្រទេសវៀតណាម ២០១៤

២. សៀវភៅណែនាំអនុវត្តអំពីហ្វាម៉ាកូវីជីឡែនឱសថប្រើនៅក្នុងការព្យាបាលជំងឺរបេងឆ្នាំ ២០១២

៣. សៀវភៅណែនាំអនុវត្តអំពីហ្វាម៉ាកូវីជីឡែនឱសថប្រឆាំងវីរុសឆ្នាំ ២០១៣

៤. សៀវភៅណែនាំអនុវត្តអំពីហ្វាម៉ាកូវីជីឡែនឱសថប្រើនៅក្នុងការព្យាបាលជំងឺគ្រុនចាញ់ឆ្នាំ ២០០៨

# មាតិកា


ជំពូក១. ហ្វាម៉ាកូវិជីឡែនសម្រាប់កម្មវិធីជាតិក្នុងកិច្ចអន្តរាគមន៍សុខភាពសាធារណៈ ........ ១

១.១. ហ្វាម៉ាកូវិជីឡែនសម្រាប់កម្មវិធីជាតិក្នុងកិច្ចអន្តរាគមន៍សុខភាពសាធារណៈ ........ ១

១.១.១. ហេតុផលក្នុងការអនុវត្តហ្វាម៉ាកូវិជីឡែនសម្រាប់កម្មវិធីជាតិក្នុងកិច្ចអន្តរាគមន៍សុខភាពសាធារណៈ.... ១

១.១.២. ទំនាក់ទំនងរវាងកម្មវិធីជាតិក្នុងកិច្ចអន្តរាគមន៍សុខភាពសាធារណៈ និងប្រព័ន្ធហ្វាម៉ាកូវិជីឡែន ........ ១

១.១.៣. កម្មវត្ថុនៃប្រព័ន្ធហ្វាម៉ាកូវិជីឡែនសម្រាប់កម្មវិធីជាតិក្នុងកិច្ចអន្តរាគមន៍សុខភាពសាធារណៈ ........ ៣

១.១.៤. វិធីសាស្ត្រក្នុងការប្រមូលព័ត៌មានអំពីសុវត្ថិភាពឱសថសម្រាប់កម្មវិធីជាតិក្នុងកិច្ចអន្តរាគមន៍សុខភាពសាធារណៈ ........ ៣

១.២.ការតាមដានប្រតិកម្មរំខានរបស់ឱសថសម្រាប់កម្មវិធីជាតិក្នុងកិច្ចអន្តរាគមន៍សុខភាពសាធារណៈ ........ ៥

១.២.១. មជ្ឈមណ្ឌលជាតិកំចាត់រោគរបេង និងហង់សិន ........ ៥

១.២.១.១ អ្នកអនុវត្ត និងវិសាលភាពការងារ ........ ៥

១.២.១.២ ការរាយការណ៍ផលរំខានរបស់ឱសថនៅមជ្ឈមណ្ឌលជាតិកំចាត់រោគរបេង និងហង់សិន ........ ៥

ក. ករណីដែលត្រូវរាយការណ៍ ........ ៥

ខ. រយៈពេលកំណត់ចុងក្រោយសម្រាប់ផ្ញើរបាយការណ៍ ........ ៨

១.២.២. មជ្ឈមណ្ឌលជាតិប្រយុទ្ធប្រឆាំងជំងឺអេដស៍ សើស្បែក និងកាមរោគ ........ ៨

១.២.២.១ អ្នកអនុវត្ត និងវិសាលភាពនៃការអនុវត្តការងារ ........ ៨

១.២.២.២ ការរាយការណ៍ប្រតិកម្មរំខានរបស់ឱសថនៅមជ្ឈមណ្ឌលជាតិប្រយុទ្ធប្រឆាំងជំងឺអេដស៍ សើស្បែក និងកាមរោគ ........ ៨

ក. មាតិកាក្នុងការរាយការណ៍ ........ ៨

ខ. ការរៀបចំ ការអនុវត្ត ........ ៩

១.២.៣. មជ្ឈមណ្ឌលជាតិប្រយុទ្ធប្រឆាំងជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រ និងបាណកសាស្ត្រ ........ ១០

១.២.៣.១ អ្នកអនុវត្ត និងវិសាលភាពនៃការអនុវត្តការងារ ........ ១០

១.២.៣.២ នីតិវិធីសម្រាប់ការរាយការណ៍ប្រតិកម្មរំខានរបស់ឱសថនៅមជ្ឈមណ្ឌលជាតិប្រយុទ្ធប្រឆាំងជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រ និងបាណកសាស្ត្រ ........ ១០

ក. វិធីសាស្ត្រនៃការរាយការណ៍ ........ ១០

ខ. មាតិកានៃការរាយការណ៍ ........ ១១

គ. នីតិវិធីក្នុងការរាយការណ៍ ........ ១១

# អក្សរកាត់

| | | |
|---|---|---|
| ADR | Adverse Drug Reaction | ប្រតិកម្មរំខានរបស់ឱសថ |
| AE | Adverse Event | ហេតុការណ៍រំខាន |
| AS | Active Surveillance | ការតាមដានសកម្ម |
| CEM | Cohort Event Monitoring | ការតាមដានហេតុការណ៍រំខានលើក្រុមអ្នកជំងឺ |
| CENAT | National TB and Leprosy Control Programme | មជ្ឈមណ្ឌលជាតិកំចាត់រោគរបេង និងហង់សិន |
| MOH | Ministry of Health | ក្រសួងសុខាភិបាល |
| NCHADS | National Center for HIV / AIDS, Dermatology and STDs | មជ្ឈមណ្ឌលជាតិប្រយុទ្ធប្រឆាំងជំងឺអេដស៍ សើស្បែក និងកាមរោគ |
| OPC | Out-Patient Clinics | គ្លីនិកពិគ្រោះជំងឺក្រៅ |
| PHPs | Public Health Programs | កម្មវិធីជាតិសុខភាពសាធារណៈ |
| PV | Pharmacovigilance | ហ្វាម៉ាកូវីជីឡែន |
| SAE | Serious Adverse Event | ហេតុការណ៍រំខានធ្ងន់ធ្ងរ |
| SR | Spontanous Reporting | ការរាយការណ៍ស្ម័គ្រចិត្ត |
| TB | Tuberculosis | ជំងឺរបេង |
| TSR | Targeted Spontaneous Reporting | ការរាយការណ៍ស្ម័គ្រចិត្តតាមទិសដៅកំណត់ |
| UMC | Uppsala Monitoring Center | មណ្ឌលតាមដានសុវត្ថិភាពឱសថនៅសាកលវិទ្យាល័យ Uppsala |
| WHO | World Health Organization | អង្គការសុខភាពពិភពលោក |

# សេចក្តីណែនាំទូទៅ

**សារបាន**:

ការតាមដានអសកម្ម (Passive Surveillance) នៃសុវត្ថិភាពឱសថ ឬការរាយការណ៍ដោយស្ម័គ្រចិត្តគឺជាចំណុចសំខាន់នៃការតាមដានសុវត្ថិភាពឱសថក្រោយដាក់លក់លើទីផ្សារ។ ការរាយការណ៍ដោយស្ម័គ្រចិត្តជាវិធីសាស្ត្រដែលគេចូលចិត្តបំផុត ហើយត្រូវគេអនុវត្តជាទម្លាប់ក្នុងការតាមដានសុវត្ថិភាពឱសថនានា។ ទោះបីជាយ៉ាងណា ដោយសារទិដ្ឋភាពនៃការព្យាបាលក្នុងប្រទេសដែលខ្វះខាតធនធានកំពុងតែធ្វើការផ្លាស់ប្តូរឱសថថ្មី ត្រូវបានគេដាក់ឱ្យប្រើលើកដំបូងដែលអាចមិនត្រូវបានគេសាកល្បងប្រើ ហើយត្រូវបានគេប្រើក្នុងប្រទេសដែលមានប្រាក់ចំណូលខ្ពស់ ដែលមានដំណើរការល្អជាប្រចាំនូវប្រព័ន្ធហ្វាម៉ាកូវីជីឡែន ឧទាហរណ៍ ការរាយការណ៍ដោយស្ម័គ្រចិត្ត ឬការតាមដានអសកម្មអាចជាវិធីសាស្ត្រល្អ ដើម្បីតាមដានសុវត្ថិភាពនៃការប្រើប្រាស់ឱសថទាំងនោះដោយសារលក្ខណៈសុវត្ថិភាពពេញលេញមិនត្រូវបានគេសិក្សា។ ដូច្នេះវិធីសាស្ត្រផ្សេងទៀតក្នុងការតាមដានសុវត្ថិភាពនៃការប្រើប្រាស់ឱសថ ដូចជាការរាយការណ៍ដោយស្ម័គ្រចិត្តដែលគេកំណត់ទិសដៅ និងការតាមដានសកម្មត្រូវបានគេអនុវត្តផងដែរ ដើម្បីតាមដានសុវត្ថិភាពការប្រើប្រាស់ឱសថសម្រាប់កម្មវិធីជាតិក្នុងកិច្ចអន្តរាគមន៍សុខភាពសាធារណៈ មណ្ឌលព័ត៌មានឱសថកម្ពុជា និងកម្មវិធីជាតិក្នុងកិច្ចអន្តរាគមន៍សុខភាពសាធារណៈត្រូវសហការគ្នាឱ្យបានប្រសើរ ដើម្បីអាចកំណត់អត្តសញ្ញាណប្រតិកម្មរំខានរបស់ឱសថឱ្យបានឆាប់រហ័ស និងចាត់វិធានការសមស្រប។ បញ្ហាខាងលើនេះជំរុញឱ្យមានការជឿជាក់លើកម្មវិធីជាតិក្នុងកិច្ចអន្តរាគមន៍សុខភាពសាធារណៈ និងលើឱសថដែលត្រូវបានដាក់បញ្ចូលក្នុងកម្មវិធីជាតិទាំងនោះសម្រាប់ការប្រើប្រាស់យ៉ាងទូលំទូលាយនៅក្នុងចំណោមប្រជាជនទូទៅ។

# ជំពូក១. ហ្វាម៉ាកូវីជីឡែនសម្រាប់កម្មវិធីជាតិក្នុងកិច្ចអន្តរាគមន៍សុខភាពសាធារណៈ

## ១.១. ហ្វាម៉ាកូវីជីឡែនសម្រាប់កម្មវិធីជាតិក្នុងកិច្ចអន្តរាគមន៍សុខភាពសាធារណៈ

### ១.១.១.ហេតុផលក្នុងការអនុវត្តហ្វាម៉ាកូវីជីឡែនសម្រាប់កម្មវិធីជាតិក្នុងកិច្ចអន្តរាគមន៍សុខភាពសាធារណៈ

កម្មវិធីជាតិក្នុងកិច្ចអន្តរាគមន៍សុខភាពសាធារណៈនៅក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវបានអនុវត្តក្នុងបរិបទដែលអត្រាប្រេវ៉ាឡង់មានកំរិតមធ្យមនៃជំងឺរបេង HIV/អេដស៍ និងកំរិតទាបនៃជំងឺគ្រុនចាញ់។ ឱសថដែលគេប្រើសម្រាប់កម្មវិធីជាតិក្នុងកិច្ចអន្តរាគមន៍សុខភាពសាធារណៈមានលក្ខណៈពិសេសច្បាស់លាស់ និងស្ថិតក្រោមការត្រួតពិនិត្យគុណភាពតឹងរ៉ឹង។ ទោះបីជាយ៉ាងណា នៅពេលគេប្រើឱសថទាំងនេះក្នុងបរិមាណច្រើនលើអ្នកជំងឺមួយចំនួនធំផ្សេងគ្នា ដូចជាកុមារ មនុស្សចាស់ ស្ត្រីមានផ្ទៃពោះ អ្នកមានប្រព័ន្ធភាពស៊ាំខ្សោយ។ល។ ឧទាហរណ៍ ការប្រើឱសថគួរតែកែតម្រូវឱ្យបានសមស្រប និងទៅតាមសុវត្ថិភាពរបស់ឱសថ។ ម្យ៉ាងទៀត ដោយសារតម្រូវការបន្ទាន់នៅក្នុងការគ្រប់គ្រង និងការកើនឡើងភាពស៊ាំជាមួយអង់ទីប៊ីយ៉ូទិក កម្មវិធីជាតិក្នុងកិច្ចអន្តរាគមន៍សុខភាពសាធារណៈត្រូវតែប្រើឱសថថ្មីៗជាច្រើនប្រភេទ និងវ៉ាក់សាំងដែលមិនទាន់បានវាយតម្លៃអំពីសុវត្ថិភាពពេញលេញ និងគ្រប់ជ្រុងជ្រោយ ជាពិសេសចំពោះអ្នកជំងឺដែលប្រើប្រាស់ឱសថរបេងថ្មីៗ កម្មវិធីជាតិក្នុងកិច្ចអន្តរាគមន៍សុខភាពសាធារណៈអាចមានផលប៉ះពាល់អវិជ្ជមានលើប្រសិទ្ធភាព និងផលចំណេញ ប្រសិនបើការតាមដានហេតុការណ៍រំខានមិនអាចធ្វើឱ្យបានគ្រប់ជ្រុងជ្រោយដើម្បីរកឱ្យឃើញ ដោះស្រាយ និងវាយតម្លៃជំបូងនូវបញ្ហាដែលទាក់ទងជាមួយនឹងសុវត្ថិភាពរបស់ឱសថដែលគេបានប្រើសម្រាប់កម្មវិធីជាតិក្នុងកិច្ចអន្តរាគមន៍សុខភាពសាធារណៈ។

ដូច្នេះការអនុវត្តសកម្មភាពហ្វាម៉ាកូវីជីឡែនសម្រាប់កម្មវិធីជាតិក្នុងកិច្ចអន្តរាគមន៍សុខភាពសាធារណៈមានសារៈសំខាន់ណាស់ ដើម្បីបង្ការប្រតិកម្មរំខានរបស់ឱសថដែលអាចកើតមាន ជាពិសេសប្រតិកម្មរំខានរបស់ឱសថធ្ងន់ធ្ងរ និងមិនបានព្រៀងទុកដើម្បីរួមចំណែកដល់ការវាយតម្លៃផលចំណេញ ឬហានិភ័យ និងជួយដល់ក្រសួងសុខាភិបាលធ្វើការសម្រេចចិត្តបានត្រឹមត្រូវដោយផ្អែកលើទិន្នន័យអំពីការប្រើប្រាស់ឱសថនៅក្នុងប្រទេស។

### ១.១.២. ទំនាក់ទំនងរវាងកម្មវិធីជាតិក្នុងកិច្ចអន្តរាគមន៍សុខភាពសាធារណៈ និងប្រព័ន្ធហ្វាម៉ាកូវីជីឡែន

មានទំនាក់ទំនងជិតស្និទ្ធទៅវិញទៅមករវាងប្រព័ន្ធហ្វាម៉ាកូវីជីឡែន និងកម្មវិធីជាតិក្នុងកិច្ចអន្តរាគមន៍សុខភាពសាធារណៈ។ កម្មវិធីជាតិក្នុងកិច្ចអន្តរាគមន៍សុខភាពសាធារណៈចូលរួមក្នុងការបង្ការ និងថែទាំការព្យាបាលតាមរយៈការប្រើឱសថនៅក្នុងសហគមន៍ ដូច្នេះហើយកម្មវិធីជាតិសុខភាពសាធារណៈអាចជួបជាមួយអ្នកជំងឺមួយចំនួនធំដើម្បីធ្វើការស្រាវជ្រាវក្នុងការតាមដានប្រតិកម្មរំខានរបស់ឱសថកើតមានចំពោះក្រុមអ្នកប្រើប្រាស់ឱសថ។ លើសពីនេះទៀត កម្មវិធីជាតិក្នុងកិច្ចអន្តរាគមន៍សុខភាពសាធារណៈជាញឹកញាប់ទទួលបានការគាំទ្រពីសំណាក់អង្គការអន្តរជាតិ និងទីភ្នាក់ងារផ្តល់ជំនួយនានា ហើយជាកម្មវិធីមួយដែលត្រូវការប្រើប្រាស់ឱសថច្រើន អង្គការទាំងនេះអាចធ្វើ ឬ

គាំទ្រកម្មវិធីបណ្ដុះបណ្ដាលប្រព័ន្ធហ្វាម៉ាកូវីជីឡែនដល់បុគ្គលិកសុខាភិបាល។ នេះជាអត្ថប្រយោជន៍មួយដើម្បីអនុវត្តសកម្មភាពប្រព័ន្ធហ្វាម៉ាកូវីជីឡែនសម្រាប់កម្មវិធីជាតិក្នុងកិច្ចអន្តរាគមន៍សុខភាពសាធារណៈ។

ប្រព័ន្ធហ្វាម៉ាកូវីជីឡែនអាចគាំទ្រកម្មវិធីជាតិក្នុងកិច្ចអន្តរាគមន៍សុខភាពសាធារណៈតាមរយៈការផ្ដល់ឱ្យនូវទិន្នន័យអំពីបញ្ហានៃការប្រើប្រាស់ឱសថ និងសុវត្ថិភាពរបស់ឱសថដែលប្រើសម្រាប់កម្មវិធីជាតិក្នុងកិច្ចអន្តរាគមន៍សុខភាពសាធារណៈដែលអាចធ្វើជាមូលដ្ឋានគ្រឹះដើម្បីផ្ដល់ការណែនាំក្នុងការកែប្រែគោលការណ៍ណែនាំស្ដីពីការធ្វើរោគវិនិច្ឆ័យ និងការព្យាបាល។ ប្រព័ន្ធហ្វាម៉ាកូវីជីឡែនអាចជួយកំណត់កត្តាហានិភ័យទាក់ទងជាមួយនឹងប្រតិកម្មរំខានរបស់ឱសថ ហើយជាលទ្ធផល សុវត្ថិភាព និងប្រសិទ្ធភាពរបស់ឱសថសម្រាប់កម្មវិធីជាតិក្នុងកិច្ចអន្តរាគមន៍សុខភាពសាធារណៈត្រូវបានពង្រឹង។ ក្រៅពីការបញ្ចូលប្រព័ន្ធហ្វាម៉ាកូវីជីឡែនសម្រាប់កម្មវិធីជាតិក្នុងកិច្ចអន្តរាគមន៍សុខភាពសាធារណៈអាចជួយដល់បុគ្គលិកសុខាភិបាលបង្កើតទម្លាប់ប្រើប្រាស់ឱសថសមស្រប និងមានសុវត្ថិភាព។

ប្រព័ន្ធហ្វាម៉ាកូវីជីឡែនសម្រាប់តាមដានសុវត្ថិភាពឱសថដែលប្រើសម្រាប់កម្មវិធីជាតិក្នុងកិច្ចអន្តរាគមន៍សុខភាពសាធារណៈដូចជាកម្មវិធីចាក់ថ្នាំបង្ការ និងកម្មវិធីគ្រប់គ្រងជំងឺរបេង HIV/អេដស៍ និងគ្រុនចាញ់ត្រូវបានគេបង្កើតនៅក្នុងប្រទេសជាច្រើន។




រូបភាពទី១. ទំនាក់ទំនងរវាងប្រព័ន្ធហ្វាម៉ាកូវីជីឡែន និងកម្មវិធីជាតិក្នុងកិច្ចអន្តរាគមន៍សុខភាពសាធារណៈ

### ១.១.៣. គម្មវត្ថុនៃប្រព័ន្ធហ្វាម៉ាកូវីជីឡែនសម្រាប់កម្មវិធីជាតិក្នុងកិច្ចអន្តរាគមន៍សុខភាពសាធារណៈ

- កំណត់ និងបន្ថយប្រេវ៉ាឡង់នៃប្រតិកម្មរំខានរបស់ឱសថសម្រាប់កម្មវិធីជាតិក្នុងកិច្ចអន្តរាគមន៍សុខភាពសាធារណៈ
- វាយតម្លៃផលប៉ះពាល់ប្រតិកម្មរំខានរបស់ឱសថលើប្រសិទ្ធភាពនៃការព្យាបាល រួមមានការបោះបង់ចោលការព្យាបាល ហេតុការណ៍រំខានបណ្តាលឱ្យមានផលវិបាកដល់អ្នកជំងឺ តម្រូវឱ្យអ្នកជំងឺចូលសម្រាកពេទ្យ ឬសម្រាកព្យាបាលក្នុងមន្ទីរពេទ្យរយៈពេលយូរ គំរាមកំហែងដល់ជីវិត អត្រាស្លាប់ និងទារកមិនគ្រប់លក្ខណៈពីកំណើត។
- កំណត់កត្តាជះឥទ្ធិពលដល់អត្រាជំងឺដែលកើតមានដំណាលគ្នា ការប្រើឱសថដំណាលគ្នា និងលក្ខណៈឱសថវិទ្យា អំពីប្រេវ៉ាឡង់របស់ប្រតិកម្មរំខានរបស់ឱសថ ប្រភេទ និងកម្រិតសភាពធ្ងន់ធ្ងរនៃប្រតិកម្មរំខានរបស់ឱសថ។
- កំណត់រកប្រតិកម្មរំខានកម្ររបស់ឱសថ និងប្រតិកម្មរំខានកើតមានបន្ទាប់ពីប្រើឱសថរយៈពេលយូរ

### ១.១.៤. វិធីសាស្ត្រក្នុងការប្រមូលព័ត៌មានអំពីសុវត្ថិភាពឱសថសម្រាប់កម្មវិធីជាតិក្នុងកិច្ចអន្តរាគមន៍សុខភាពសាធារណៈ

វិធីសាស្ត្រទូទៅក្នុងការប្រមូលព័ត៌មានអំពីសុវត្ថិភាពឱសថដែលប្រើសម្រាប់កម្មវិធីជាតិក្នុងកិច្ចអន្តរាគមន៍សុខភាពសាធារណៈរួមមាន៖

- ការរាយការណ៍ដោយស្ម័គ្រចិត្ត
- ការរាយការណ៍ដោយស្ម័គ្រចិត្តដែលគេកំណត់ទិសដៅ
- ការតាមដានសកម្ម

**ការរាយការណ៍ដោយស្ម័គ្រចិត្ត៖**

ការរាយការណ៍ដោយស្ម័គ្រចិត្តជាវិធីសាស្ត្រតាមដានដែលគេប្រើញឹកញាប់បំផុត។ វាជា បព័ន្ធងាយស្រួលបំផុតក្នុងការបង្កើតហើយមានតម្លៃថោក។ វាជាវិធីសាស្ត្រដែលអនុវត្តបានគ្រប់ឱសថទាំងអស់។ ទោះបីយ៉ាងណាក៏ដោយដែនកំណត់ចំបងរបស់ប្រព័ន្ធនេះគឺថាមានការរាយការណ៍តិចតួច និងព័ត៌មានក្នុងការរាយការណ៍មិនពេញលេញដោយសារការរាយការណ៍ប្រតិកម្មរំខានរបស់ឱសថដែលអាចកើតមានគឺអាស្រ័យការយល់ដឹង ការផ្តួចផ្តើមគំនិត និងការលើកទឹកចិត្តរបស់អ្នករាយការណ៍ ហើយប្រព័ន្ធរាយការណ៍នេះត្រូវបានគេគិតថាជាប្រព័ន្ធអសកម្ម ឬស្ម័គ្រចិត្ត។

**ការរាយការណ៍ស្ម័គ្រចិត្តដែលគេកំណត់ទិសដៅ៖**

ការរាយការណ៍ស្ម័គ្រចិត្តដែលកំណត់ទិសដៅគឺជាការប្រែប្រួលមួយនៃការរាយការណ៍ស្ម័គ្រចិត្ត។ វាផ្តោតទៅលើការប្រមូលយកប្រតិកម្មរំខានរបស់ឱសថនៅក្នុងក្រុមអ្នកជំងឺជាក់លាក់ដែលកំពុងព្យាបាល។ បុគ្គលិកសុខាភិបាលដែលទទួលបន្ទុកអ្នកជំងឺត្រូវយល់ដឹងឱ្យច្រើនក្នុងការរាយការណ៍អំពីបញ្ហាសុវត្ថិភាពជាក់លាក់របស់ឱសថ។ ការរាយការណ៍ស្ម័គ្រចិត្តដែលកំណត់ទិសដៅនេះមានគោលបំណងដើម្បីធានាថាអ្នកជំងឺត្រូវបានតាមដាន និងថាប្រតិកម្មរំខានរបស់ឱសថត្រូវបានគេរាយការណ៍ជាសមាសធាតុផ្សំធម្មតានៃការតាមដានអ្នកជំងឺជាប្រចាំ ហើយដើម្បីទទួលបានការថែទាំតាមស្តង់ដារដែលបានកំណត់។ វិធីសាស្ត្រនេះមានគោលបំណងដូចគ្នា និងលំហូរព័ត៌មានដូចការរាយការណ៍ស្ម័គ្រចិត្តដែរ។ ការរាយការណ៍នេះមិនតម្រូវឱ្យមានវិធានការសកម្មដើម្បីរកពេគសញ្ញាពិសេសណាមួយនោះទេ។

**ការតាមដានសកម្មៈ**

ការតាមដានសកម្មអំពីសុវត្ថិភាពឱសថ (ឬការត្រៀមទុកជាមុន) មានន័យថាវិធានការសកម្មនានាត្រូវបានគេប្រកាន់យកដើម្បីរកឱ្យឃើញនូវហេតុការណ៍រំខានផ្សេងៗរបស់ឱសថ។ ការរាយការណ៍នេះសម្រេចបានតាមរយៈការតាមដានសកម្មបន្ទាប់ពីព្យាបាល និងហេតុការណ៍នេះគេអាចរកឃើញតាមរយៈការសួរអ្នកជំងឺផ្ទាល់ ឬការត្រួតពិនិត្យកំណត់ជំងឺរបស់អ្នកជំងឺ។ ជាការល្អបំផុតគឺត្រូវអនុវត្តមុនពេលផលរំខានឱសថកើតឡើង។ ហ្វាម៉ាកូវីជីឡែនសកម្មជួនកាលត្រូវការប្រើប្រាស់ភាសាលំអិតដែលសំដៅទៅលើ "ការតាមដានទាន់ហេតុការណ៍"។ វិធីសាស្ត្រទូទៅគ្រប់ជ្រុងជ្រោយបំផុតគឺការតាមដានហេតុការណ៍រំខានលើអ្នកជំងឺជាក្រុម វាជាវិធីសាស្ត្រដែលអាចកែសម្រួលបាន និងមានប្រសិទ្ធភាពដើម្បីប្រមូលទិន្នន័យល្អគ្រប់ជ្រុងជ្រោយ។ វិធីសាស្ត្រនេះត្រូវបានគេគ្រោងទុក និងអនុវត្តស្រដៀងគ្នាទៅនឹងការសិក្សាអំពីអ្នកជំងឺជាក្រុមនៅក្នុងអេពីដេមីសាស្ត្រដែលត្រូវបានគេប្រើដើម្បីរកហេតុការណ៍រំខានថ្មីៗ ជាពិសេស ឱសថថ្មី ឬដើម្បីប្រមូលព័ត៌មានស្តីអំពីហេតុការណ៍រំខានដែលគេដឹង។ វិធីសាស្ត្រត្រូវបានគេប្រើយ៉ាងទូលាយសម្រាប់កម្មវិធីជាតិក្នុងកិច្ចអន្តរាគមន៍សុខភាពសាធារណៈ។ វិធីសាស្ត្រផ្សេងទៀតនៃការតាមដានសកម្មរួមមាន ការប្រើប្រាស់សៀវភៅចុះបញ្ជីទាក់ទងកំណត់ត្រាអ្នកជំងឺ និងការពិនិត្យលទ្ធផលមន្ទីរពិសោធន៍នៅក្នុងមន្ទីរពិសោធន៍វេជ្ជសាស្ត្រ។

ជំហានសំខាន់ផ្សេងទៀតនៃការវាយតម្លៃហេតុនិងផល និងការរកឃើញសញ្ញាណត្រូវបានអនុវត្តចំពោះវិធីសាស្ត្រទាំងបីនេះ។ ការរាយការណ៍ដោយស្ម័គ្រចិត្ត និងការរាយការណ៍ស្ម័គ្រចិត្តដែលគេកំណត់ទិសដៅអាចអនុវត្តបានសម្រាប់ការតាមដានហេតុការណ៍រំខានជាប្រចាំនៅក្នុងមូលដ្ឋានសុខាភិបាលស្ថិតនៅក្រោមកម្មវិធីជាតិក្នុងកិច្ចអន្តរាគមន៍សុខភាពសាធារណៈ។ ការរាយការណ៍ដោយស្ម័គ្រចិត្តផ្តោតលើការប្រមូលប្រតិកម្មរំខានរបស់ឱសថគ្រប់ប្រភេទ រីឯការរាយការណ៍ស្ម័គ្រចិត្តដែលគេកំណត់ទិសដៅផ្តោតលើការតាមដាន និងការរាយការណ៍ទៅតាមលក្ខណៈពិតប្រាកដមួយចំនួន (ដូចជាក្រុមអ្នកជំងឺពិតប្រាកដ ប្រតិកម្មរំខានរបស់ឱសថពិតប្រាកដមួយចំនួន)។ ដូច្នេះ ការរាយការណ៍ស្ម័គ្រចិត្តដែលគេកំណត់ទិសដៅបើប្រៀបធៀបទៅ វាមានលក្ខណៈត្រឹមត្រូវសម្រាប់អនុវត្តនៅក្នុងកម្មវិធីជាតិក្នុងកិច្ចអន្តរាគមន៍សុខភាពសាធារណៈដោយសារវាអាចធ្វើឱ្យគុណភាពរបាយការណ៍ល្អប្រសើរ និងកាត់បន្ថយបន្ទុកការងាររបស់បុគ្គលិកសុខាភិបាលបើប្រៀបធៀបទៅនឹងការរាយការណ៍ដោយស្ម័គ្រចិត្ត។

**១.២.ការតាមដានប្រតិកម្មរំខានរបស់ឱសថសម្រាប់កម្មវិធីជាតិក្នុងកិច្ចអន្តរាគមន៍សុខភាពសាធារណៈ**

**១.២.១. មជ្ឈមណ្ឌលជាតិកំចាត់រោគរបេង និងហង់សិន**

**១.២.១.១. អ្នកអនុវត្ត និងវិសាលភាពការងារ**

*វិសាលភាពអនុវត្តការងារ៖* មូលដ្ឋានសុខាភិបាលសាធារណៈដែលមានព្យាបាលជំងឺរបេង អង្គភាពគ្រប់គ្រងការព្យាបាលជំងឺរបេងក្នុងសហគមន៍។

*បុគ្គលដែលទាក់ទងនឹងការរាយការណ៍៖* វេជ្ជបណ្ឌិត ឱសថការី គិលានុបដ្ឋាក ឆ្មប អ្នកប្រកបវិជ្ជាជីវៈក្នុងវិស័យសុខាភិបាល អ្នកគ្រប់គ្រងសហគមន៍ អ្នកជំងឺនិងក្រុមគ្រួសារពួកគាត់។ ការលើកទឹកចិត្តត្រូវបានផ្ដល់ឱ្យដល់ប្រជាជនទូទៅក្នុងការបំពេញរបាយការណ៍ដើម្បីរាយការណ៍ផលរំខានរបស់ឱសថ។

**១.២.១.២. ការរាយការណ៍ផលរំខានរបស់ឱសថនៅមជ្ឈមណ្ឌលជាតិកំចាត់រោគរបេង និងហង់សិន**

នៅមជ្ឈមណ្ឌលជាតិកំចាត់រោគរបេង និងហង់សិនការកំណត់រក ការគ្រប់គ្រង ការរាយការណ៍ និងការបង្ការផលរំខានរបស់ឱសថត្រូវបានធ្វើឡើងតាមគោលការណ៍ដែលអនុវត្តចំពោះគ្រប់ឱសថផ្សេងទៀត និងក្នុងពេលជំណាលគ្នា ផលរំខានរបស់ឱសថមានលក្ខណៈពិសេសច្បាស់លាស់របស់ឱសថនីមួយៗ។ ចំណុចមួយចំនួនត្រូវការយកមកពិចារណានៅពេលគេធ្វើរបាយការណ៍ផលរំខានរបស់ឱសថនៅមជ្ឈមណ្ឌលជាតិកំចាត់រោគរបេង និងហង់សិនដូចតទៅនេះ៖

**ក. ករណីដែលត្រូវរាយការណ៍**

របាយការណ៍ផលរំខានរបស់ឱសថដាច់ដោយឡែកមួយសម្រាប់អ្នកជំងឺម្នាក់ៗពេលដែលរកឃើញ ឬសង្ស័យមានផលរំខានរបស់ឱសថត្រូវបានគេសរសេរ។ គ្រប់ហេតុការណ៍រំខានទាំងអស់ដែលកើតចេញពីដំណើរការព្យាបាលជំងឺរបេងដោយសង្ស័យថាមានផលរំខានរបស់ឱសថដែលបង្កដោយឱសថព្យាបាលជំងឺរបេង និងឱសថប្រើរួមផ្សំគ្នាគួរត្រូវរាយការណ៍។ ករណីដូចខាងក្រោមនេះត្រូវរាយការណ៍ជាអាទិភាព៖

ហេតុការណ៍រំខានធ្ងន់ធ្ងរ៖ ប្រតិកម្មដែលបណ្តាលឱ្យមានបញ្ហាមួយនៃបញ្ហាទិន្នផលដូចតទៅនេះ៖ ការស្លាប់ ការគំរាមកំហែងជីវិត ការចូលសម្រាកព្យាបាលក្នុងមន្ទីរពេទ្យ ឬការពន្យារពេលការចូលសម្រាកពេទ្យរបស់អ្នកជំងឺ ការចាំបាច់ត្រូវប្ដូរកម្រិតព្យាបាល ពិការភាព ឬអសមត្ថភាពជាអចិន្ត្រៃយ៍ អ្នកជំងឺឈប់ប្រើឱសថដោយខ្លួនឯងអំឡុងពេលព្យាបាល អ្នកជំងឺពិគ្រោះក្រៅ ឬផលរំខានរបស់ឱសថណាមួយដែលបុគ្គលិកសុខាភិបាលគិតថាជាទិន្នផលដែលមានរោគសញ្ញាគ្លីនិកធ្ងន់ធ្ងរ។

ប្រតិកម្មរំខានថ្មីៗរបស់ឱសថព្យាបាលជំងឺរបេងដែលគេមិនទាន់ដឹងនៅឡើយ គ្មានការរៀបរាប់ក្នុងបរិយាយប័ណ្ណឱសថ ឬគ្មានព័ត៌មានក្នុងឯកសារយោងឱសថផ្សេងទៀត។

ផលរំខានរបស់ឱសថកើតមានញឹកញាប់ក្នុងរយៈពេលខ្លីនៅក្នុងមូលដ្ឋានសុខាភិបាលដោយឱសថមួយ ឬឡូត៍មួយរបស់ឱសថ។

ការលើកទឹកចិត្តត្រូវបានផ្តល់ឱ្យដល់បុគ្គលិកសុខាភិបាលក្នុងការរាយការណ៍អំពីគុណភាពឱសថ និងការភាន់ច្រឡំ ( Medication Errors )។




រូបភាពទី២. នីតិវិធីក្នុងការរាយការណ៍ប្រតិកម្មរំខានរបស់ឱសថព្យាបាលជំងឺរបេង

### ខ. រយៈពេលកំណត់ចុងក្រោយសម្រាប់ផ្ញើរបាយការណ៍

របាយការណ៍ត្រូវធ្វើឱ្យបានឆាប់នៅពេលកើតមានប្រតិកម្មរំខាន សូម្បីតែព័ត៌មានដែលប្រមូលមិនទាន់គ្រប់គ្រាន់ក៏ដោយ (របាយការណ៍ដំបូង)។ ក្នុងករណីនេះអាចផ្ញើរបាយការណ៍បន្ថែមទៀត បើសិនមានព័ត៌មានបន្ថែមទៀត (របាយការណ៍តាមដាន)។

ត្រូវធានាថារបាយការណ៍ត្រូវផ្ញើមកមណ្ឌលព័ត៌មានឱសថកម្ពុជាឱ្យទាន់ពេលវេលា៖

- របាយការណ៍អំពីហេតុការណ៍រំខានធ្ងន់ធ្ងរដែលទាក់ទងនឹងការស្លាប់ គំរាមកំហែងជីវិត អ្នកជំងឺត្រូវធ្វើឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន ប៉ុន្តែមិនយឺតជាង៧ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីរកឃើញប្រតិកម្មរំខាន។
- របាយការណ៍ផ្សេងទៀតអំពីហេតុការណ៍រំខានធ្ងន់ធ្ងរត្រូវផ្ញើរបាយការណ៍ឱ្យឆាប់ដែលអាចធ្វើបាន ប៉ុន្តែមិនយឺតជាង១៥ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីរកឃើញប្រតិកម្មរំខាន។
- របាយការណ៍ផ្សេងទៀតអំពីហេតុការណ៍រំខានត្រូវផ្ញើមកឱ្យបានទៀងទាត់។

*នីតិវិធីក្នុងការរាយការណ៍៖*

បំពេញទំរង់របាយការណ៍ប្រតិកម្មរំខានរបស់ឱសថដែលសង្ស័យ ហើយផ្ញើរបាយការណ៍ឱសថព្យាបាលរបេងទៅតាមនីតិវិធីដូចក្នុងរូបភាពទី២ ទោះបីជាការព្យាបាលអ្នកជំងឺធ្វើនៅក្នុងមន្ទីរពេទ្យ ឬអ្នកជំងឺពិគ្រោះក្រៅក៏ដោយ។

គ្រប់របាយការណ៍គួរបំពេញឱ្យឆាប់ដែលអាចធ្វើទៅបាន ហើយផ្ញើទៅមណ្ឌលព័ត៌មានឱសថកម្ពុជា។ របាយការណ៍នីមួយៗនឹងត្រូវបានគេរៀបចំទុកដាក់ និងវាយតម្លៃដោយមណ្ឌលព័ត៌មានឱសថកម្ពុជា និងរាយការណ៍ត្រឡប់ទៅអ្នករាយការណ៍វិញចំពោះករណីពិសេសខ្លះ។ ទិន្នន័យប្រតិកម្មរំខានរបស់ឱសថទាក់ទងទៅនឹងឱសថព្យាបាលជំងឺរបេងនឹងត្រូវដាក់បញ្ចូលគ្នា ហើយផ្ញើជូនមជ្ឈមណ្ឌលជាតិកំចាត់រោគរបេង និងហង់សិនទៅតាមពេលវេលាកំណត់។

## ១.២.២. មជ្ឈមណ្ឌលជាតិប្រយុទ្ធប្រឆាំងជំងឺអេដស៍ សើស្បែក និងកាមរោគ

### ១.២.២.១. អ្នកអនុវត្ត និងវិសាលភាពនៃការអនុវត្តការងារ

វិសាលភាពនៃការអនុវត្តការងារៈ ការព្យាបាលដោយឱសថប្រឆាំងវីរុសនៅមូលដ្ឋានសុខាភិបាល។

បុគ្គលិកដែលអនុវត្ត៖ វេជ្ជបណ្ឌិត ជំនួយការវេជ្ជបណ្ឌិត ឱសថការី ជំនួយការឱសថស្ថាន គិលានុបដ្ឋាក អ្នកពិគ្រោះយោបល់ និងបុគ្គលិកសុខាភិបាលផ្សេងទៀតនៅក្នុងកម្មវិធីបង្ការ និងគ្រប់គ្រងជំងឺ HIV/AIDS។

### ១.២.២.២. ការរាយការណ៍ប្រតិកម្មរំខានរបស់ឱសថនៅមជ្ឈមណ្ឌលជាតិប្រយុទ្ធប្រឆាំងជំងឺអេដស៍ សើស្បែក និងកាមរោគ

### ក. មាតិកាក្នុងការរាយការណ៍

- **របាយការណ៍ទៅតាមពេលៈ** របាយការណ៍ប្រចាំខែអំពីប្រតិកម្មរំខានរបស់ឱសថនៃឱសថប្រឆាំងវីរុស
- **របាយការណ៍តែមួយៈ** ការរាយការណ៍រាល់ហេតុការណ៍រំខានដែលកើតមានពេលព្យាបាលដោយសង្ស័យថាមានប្រតិកម្មរំខានបង្កដោយឱសថប្រឆាំងវីរុស ឬឱសថផ្សេងដែលគេប្រើរួមផ្សំសម្រាប់អ្នកជំងឺ HIV/AIDS។

- គោលការណ៍ណែនាំសម្រាប់តាមដានប្រតិកម្មរំខានរបស់ឱសថប្រឆាំងវីរុសក្នុងកម្មវិធីបង្ការ និងគ្រប់គ្រងជំងឺHIV/AIDS:
  - ប្រតិកម្មរំខានរបស់ឱសថធ្ងន់ធ្ងរ
  - ប្រតិកម្មណាមួយដែលបង្កឱ្យមានហេតុការណ៍មួយក្នុងហេតុការណ៍ដូចតទៅនេះ៖ ការប្រែប្រួលកម្រិតព្យាបាល ការបញ្ឈប់ការព្យាបាល ឬការតម្រូវឱ្យមានការព្យាបាលដើម្បីធ្វើឱ្យធូរស្រាលប្រតិកម្មរំខាន។
  - ប្រតិកម្មរំខានរបស់ឱសថណាមួយដែលត្រូវបានវាយតម្លៃដោយបុគ្គលិកសុខាភិបាលថាបណ្តាលឱ្យមានរោគសញ្ញាគ្លីនិកធ្ងន់ធ្ងរ ។
  - រាល់ប្រតិកម្មរំខានរបស់ឱសថថ្មី កម្រិតប្រើថ្មី
  - ប្រតិកម្មរំខានរបស់ឱសថថ្មីដែលគេមិនទាន់ស្គាល់(មិនមានការរៀបរាប់នៅក្នុងគោលការណ៍ណែនាំថ្នាក់ជាតិសម្រាប់ប្រើក្នុងការព្យាបាលដោយឱសថប្រឆាំងវីរុស ចំពោះមនុស្សពេញវ័យ និងវ័យជំទង់នៅក្នុងបរិយាយប័ណ្ណឱសថ ឬមិនមានព័ត៌មាននៅក្នុងឯកសារយោងឱសថផ្សេងទៀត)។ ប្រតិកម្មរំខានរបស់ឱសថធ្ងន់ធ្ងរទាំងនោះទំនងកើតឡើងដោយសារការភាន់ច្រឡំ(Medication Errors)ប្រតិកម្មចាប់ផ្តើមឱ្យការព្រួយបារម្ភរបស់មាតាបិតា និងសហគមន៍ ប្រតិកម្មស្រាល ប៉ុន្តែកើតមានញឹកញាប់ខុសធម្មតា គួររាយការណ៍អំឡុងពេល២៤ម៉ោង បន្ទាប់ពីទទួលព័ត៌មាន ហើយរាយការណ៍ប្រចាំសប្តាហ៍អំពីការវិវត្តន៍នៃការតាមដាន និងការគ្រប់គ្រង។

## ខ. ការរៀបចំ ការអនុវត្ត

- មជ្ឈមណ្ឌលជាតិប្រយុទ្ធប្រឆាំងជំងឺអេដស៍សើស្បែកនិងកាមរោគ
  - ទទួលរបាយការណ៍ដែលផ្ញើមកពីរាជធានីខេត្ត ( បូកសរុប វិភាគ ផ្តល់អនុសាសន៍ )
  - សហការជាមួយអង្គភាពដើម្បីធ្វើការណែនាំ ការគ្រប់គ្រង ( បើសិនមាន ) ចំពោះឱសថប្រឆាំងវីរុស (ARV) ដែលមានប្រតិកម្មទៅតាមកម្រិតខុសគ្នាៗ។
  - ធ្វើការត្រួតពិនិត្យ និងគ្រប់គ្រងការតាមដានឱសថប្រឆាំងវីរុស (ARV) នៅថ្នាក់រាជធានីខេត្ត។
- មណ្ឌលព័ត៌មានឱសថថ្នាក់ជាតិ
  - ទទួល វិភាគ ផ្តល់ព័ត៌មានត្រឡប់ចំពោះរបាយការណ៍តែមួយ និងរបាយការណ៍តាមពេលវេលាពីកន្លែងព្យាបាលនានា។ ផ្តល់ព័ត៌មានត្រឡប់អំពីប្រតិកម្មរំខានរបស់ឱសថធ្ងន់ធ្ងរឱ្យបានឆាប់ទៅកាន់អង្គភាពពាក់ព័ន្ធ។
  - បូកសរុបប្រចាំខែ វិភាគរបាយការណ៍ប្រតិកម្មរំខានរបស់ឱសថប្រឆាំងវីរុស (ARV) ផ្តល់អនុសាសន៍ និងព័ត៌មានត្រឡប់ទៅកាន់មជ្ឈមណ្ឌលជាតិប្រយុទ្ធប្រឆាំងជំងឺអេដស៍សើស្បែក និងកាមរោគនិងអង្គភាពពាក់ព័ន្ធ។

- មូលដ្ឋានព្យាបាល
  - ធ្វើរបាយការណ៍ប្រតិកម្មរំខានរបស់ឱសថទៅតាមកាលវិភាគដូចតទៅ៖
    - ➢ រាយការណ៍ហេតុការណ៍រំខានធ្ងន់ធ្ងរដែលបណ្តាលឱ្យស្លាប់ ឬគំរាមជីវិតអ្នកជំងឺ (កម្រិត៤)៖ ត្រូវធ្វើឱ្យបានឆាប់ដែលអាចធ្វើទៅបាន ប៉ុន្តែមិនយឺតជាង៧ថ្ងៃធ្វើការ បន្ទាប់ពីរកឃើញប្រតិកម្មកើតមាន។
    - ➢ រាយការណ៍ហេតុការណ៍រំខានធ្ងន់ធ្ងរកម្រិត៣៖ ត្រូវធ្វើឱ្យឆាប់ដែលអាចធ្វើទៅបាន ប៉ុន្តែមិនយឺតជាង ១៥ថ្ងៃធ្វើការ បន្ទាប់ពីរកឃើញប្រតិកម្មកើតមាន។
    - ➢ របាយការណ៍ប្រតិកម្មរំខានរបស់ឱសថផ្សេងទៀតអាចរួមបញ្ចូលគ្នា ដើម្បីធ្វើប្រចាំខែមុនថ្ងៃទី៥នៃខែបន្ទាប់។
    - ➢ របាយការណ៍ត្រូវធ្វើឱ្យបានឆាប់នៅពេលដែលមានការកើតមានប្រតិកម្មរំខាន សូម្បីតែព័ត៌មានដែលទទួលបាននៅមិនទាន់គ្រប់ជ្រុងជ្រោយក៏ដោយ (របាយការណ៍ដំបូង)។ ក្នុងករណីនេះអាចធ្វើបន្ថែមរបាយការណ៍ទៀត បើសិនប្រមូលបានព័ត៌មានបន្ថែម (របាយការណ៍តាមដាន)។
  - ធ្វើរបាយការណ៍តាមពេលប្រចាំខែនៅមូលដ្ឋានព្យាបាល ហើយរាយការណ៍ជូនមជ្ឈមណ្ឌលជាតិប្រយុទ្ធប្រឆាំងជំងឺអេដស៍សើស្បែក និងកាមរោគមុនថ្ងៃទី៥នៃខែបន្ទាប់។

### ១.២.៣. មជ្ឈមណ្ឌលជាតិប្រយុទ្ធប្រឆាំងជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រ និងបាណកសាស្ត្រ

#### ១.២.៣.១.បុគ្គលអនុវត្ត និងវិសាលភាពអនុវត្តការងារ

*បុគ្គលអនុវត្តការងារ:* ការតាមដានប្រតិកម្មរំខានរបស់ឱសថគ្រុនចាញ់គឺជាការទទួលខុសត្រូវរបស់បុគ្គលសុខាភិបាលរួមមាន វេជ្ជបណ្ឌិត ជំនួយការវេជ្ជបណ្ឌិត ឱសថការី ជំនួយការឱសថស្ថាន គិលានុបដ្ឋាក ឆ្មប អ្នកបច្ចេកទេសមន្ទីរពិសោធន៍ និងបុគ្គលិកសុខាភិបាលផ្សេងទៀតនៅមូលដ្ឋានសុខាភិបាល។

*វិសាលភាពនៃការអនុវត្តការងារ៖* មូលដ្ឋានសុខាភិបាល និងគ្លីនិកពិគ្រោះជំងឺក្រៅដែលព្យាបាលអ្នកជំងឺគ្រុនចាញ់ កម្មវិធីជំងឺគ្រុនចាញ់តាមខេត្តទូទាំងប្រទេស។

#### ១.២.៣.២.នីតិវិធីសម្រាប់ការរាយការណ៍ប្រតិកម្មរំខានរបស់ឱសថនៅមជ្ឈមណ្ឌលជាតិប្រយុទ្ធប្រឆាំងជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រ និងបាណកសាស្ត្រ

**ក.វិធីសាស្ត្រនៃការរាយការណ៍**

របាយការណ៍មួយត្រូវបានធ្វើសម្រាប់គ្រប់ហេតុការណ៍រំខានទាំងអស់ដែលកើតមានពេលកំពុងព្យាបាលដោយមានការសង្ស័យមានប្រតិកម្មរំខានបង្កដោយឱសថព្យាបាលជំងឺគ្រុនចាញ់ ឬឱសថប្រើរួមផ្សំសម្រាប់អ្នកជំងឺគ្រុនចាញ់ ជាពិសេសអាទិភាពត្រូវផ្តល់ឱ្យចំពោះការរាយការណ៍៖

- **ហេតុការណ៍រំខានធ្ងន់ធ្ងរ៖** ប្រតិកម្មណាមួយដែលបណ្តាលឱ្យមានទិន្នផលដូចតទៅនេះ៖ ការស្លាប់ គំរាមជីវិត ការចូលគេងពេទ្យ ឬពន្យារការគេងពេទ្យរបស់អ្នកជំងឺតម្រូវឱ្យមានការកែប្រែកម្រិតព្យាបាល ពិការភាព/អសមត្ថភាពអចិន្ត្រៃយ៍ ឬខ្លាំងប៉ះពាល់ទារកក្នុងផ្ទៃ ឬប្រតិកម្មរំខានរបស់ឱសថណាមួយដែលបុគ្គលិកសុខាភិបាលគិតថាផ្តល់ឱ្យមានរោគសញ្ញាធ្ងន់ធ្ងរ។
- ប្រតិកម្មរំខានថ្មីរបស់ឱសថព្យាបាលគ្រុនចាញ់ដែលមិនត្រូវបានគេស្គាល់ (គ្មានការរៀបរាប់ក្នុងគោលការណ៍ណែនាំរបស់ក្រសួងសុខាភិបាលអំពីរោគវិនិច្ឆ័យ ការព្យាបាល និងបង្ការជំងឺគ្រុនចាញ់ គ្មាននៅក្នុងបរិយាយប័ណ្ណឱសថ ឬគ្មានក្នុងព័ត៌មានឯកសារយោងឱសថផ្សេងទៀត)។
- ប្រតិកម្មរំខានបង្កដោយឱសថកើតមានញឹកញាប់ក្នុងរយៈពេលខ្លីនៅមូលដ្ឋានសុខាភិបាលដោយឱសថមួយមុខ ឬឱសថមួយឡូត៍។

ផ្តល់ការលើកទឹកចិត្តដល់បុគ្គលិកសុខាភិបាលឱ្យរាយការណ៍អំពីគុណភាពឱសថ និងការភាន់ច្រឡំ (Medication Errors)។

## ខ. មាតិកានៃការរាយការណ៍

បំពេញព័ត៌មានពេញលេញក្នុងទំរង់របាយការណ៍ប្រតិកម្មរំខានរបស់ឱសថចំពោះឱសថព្យាបាលគ្រុនចាញ់រួមមាន៖

- ឈ្មោះមូលដ្ឋានសុខាភិបាល និងលេខកូដរាយការណ៍របស់អង្គភាព (បើសិនអនុវត្ត)
- ព័ត៌មានអំពីអ្នកជំងឺ៖ ឈ្មោះពេញ ថ្ងៃខែឆ្នាំកំណើត ឬអាយុ ភេទ ទម្ងន់ ក្រុមជាតិសាសន៍ ប្រវត្តិអាល្លែកហ្ស៊ីពីមុន ការជក់បារី ការផឹកស្រា មានជំងឺថ្លើម ឬតម្រងនោម ឬអត់លទ្ធផលតេស្តប៉ារ៉ាស៊ីតជំងឺគ្រុនចាញ់
- ព័ត៌មានអំពីប្រតិកម្មរំខាន៖ កាលបរិច្ឆេទនៃការកើតមាន ពេលកើតមាន រោគសញ្ញាប្រតិកម្ម តេស្តពាក់ព័ន្ធ និងវិធីសាស្ត្រគ្រប់គ្រង សភាពប្រតិកម្ម និងទិន្នផលនៃការគ្រប់គ្រងប្រតិកម្ម
- ឱសថដែលសង្ស័យបង្កប្រតិកម្មរំខានរបស់ឱសថ៖ ក្នុងចំណោមឱសថព្យាបាលគ្រុនចាញ់ដែលមានឈ្មោះ រូបភាពឱសថ និងសមាសធាតុផ្សំ ព័ត៌មានបន្ថែមដែលទាក់ទងទៅនឹងឱសថគ្រុនចាញ់ដែលសង្ស័យបង្កប្រតិកម្មរំខានរបស់ឱសថគឺចាំបាច់ (ដូចជាឈ្មោះរោងចក្រផលិត លេខឡូត៍ កម្រិតប្រើ ផ្លូវប្រើប្រាស់ ថ្ងៃចាប់ផ្តើម និងថ្ងៃឈប់ប្រើឱសថ) ការធូរស្រាលពីប្រតិកម្មរំខាន បន្ទាប់ពីបញ្ឈប់ប្រើ/បន្ថយកម្រិតប្រើណាមួយ ការកើតមានប្រតិកម្មឡើងវិញនៅពេលបន្តប្រើឱសថដែលសង្ស័យ ព័ត៌មានអំពីឱសថដែលប្រើរួមផ្សំគ្នា (ឈ្មោះឱសថ រូបភាពឱសថ សមាសធាតុផ្សំ ផ្លូវប្រើប្រាស់ កម្រិតប្រើម្តងៗ ចំនួនដងក្នុង១ថ្ងៃ កម្រិតប្រើសរុប ហេតុផលក្នុងការប្រើឱសថ ចាប់ផ្តើម និងបញ្ឈប់ការប្រើឱសថ)។
- ព័ត៌មានអំពីអ្នករាយការណ៍ (ឈ្មោះពេញ មុខរបរ/ឋានៈ លេខទូរស័ព្ទទាក់ទង អ៊ីមែល ហត្ថលេខា ប្រភេទរបាយការណ៍ និងកាលបរិច្ឆេទការរាយការណ៍)។

## គ. នីតិវិធីក្នុងការរាយការណ៍

មូលដ្ឋានសុខាភិបាលព្យាបាល គ្លីនិកពិគ្រោះជំងឺក្រៅ កម្មវិធីគ្រុនចាញ់ខេត្ត ផ្ញើរបាយការណ៍ដោយផ្ទាល់មកកាន់មណ្ឌលព័ត៌មានឱសថស្របតាមកាលវិភាគដូចតទៅនេះ៖

- របាយការណ៍ត្រូវផ្ញើឱ្យបានឆាប់រហ័សនៅពេលដែលមានការកកើតប្រតិកម្មរំខាន សូម្បីតែព័ត៌មានដែលប្រមូលបាននៅមិនទាន់គ្រប់គ្រាន់ (ការរាយការណ៍ដំបូង) ក្នុងករណីនេះអាចផ្ញើរបាយការណ៍បន្ថែមទៀត បើសិនទទួលបានព័ត៌មានបន្ថែមទៀត (របាយការណ៍តាមដាន)។
- ត្រូវធានាថារបាយការណ៍ត្រូវបានផ្ញើទៅមណ្ឌលព័ត៌មានឱសថទាន់ពេលវេលាៈ
  - រាយការណ៍ហេតុការណ៍រំខានធ្ងន់ធ្ងរដែលបណ្តាលឱ្យស្លាប់ ឬគំរាមជីវិតអ្នកជំងឺត្រូវផ្ញើឱ្យបានឆាប់ដែលអាចធ្វើទៅបាន ប៉ុន្តែមិនយឺតជាង៧ថ្ងៃធ្វើការ បន្ទាប់ពីរកឃើញប្រតិកម្មរំខាន។
  - រាយការណ៍ហេតុការណ៍រំខានធ្ងន់ធ្ងរផ្សេងទៀត៖ ត្រូវផ្ញើឱ្យឆាប់ដែលអាចធ្វើទៅបាន ប៉ុន្តែមិនយឺតជាង ១៥ថ្ងៃធ្វើការ បន្ទាប់ពីរកឃើញប្រតិកម្មរំខាន។
  - របាយការណ៍អំពីហេតុការណ៍រំខានផ្សេងទៀតបូកសរុប ដើម្បីផ្ញើប្រចាំខែមុនថ្ងៃទី៥នៃខែបន្ទាប់។